


# ញ៉ុកថែម

NHOK THEM

(១៩០៣ - ១៩៧៤)

*រៀបរៀងដោយ*

*បណ្ឌិតសភាចារ្យ* **ឃីងហុកឌី**

***កំណើត៖***

**ញ៉ុកថែម**_កើតនៅថ្ងៃសៅរ៍១១រោចខែជេស្ឋឆ្នាំថោះគឺត្រូវនឹងថ្ងៃ ២២មិថុនា១៩០៣ក្នុងភូមិរតនៈ សង្កាត់ស្វាយប៉ោស្រុក ខេត្ត បាត់ដំបង។_

លោកជាបុត្រច្បងលោក**ញ៉ុក ញ៉ុំ**និងអ្នកស្រី**ហៀក**មានអជីវកម្មជាជាងទង។ ក្រោមមកមាតាបិតាលះបង់អជីវកម្មនេះចេញទៅជាកសិករនៅភូមិអូរតាគី សង្កាត់ជ្រៃស្រុក ខេត្របាត់ដំបង។

## ការសិក្សាជាសង្ឃនិងជីវិតជាគ្រហស្ថ

អាយុប្រមាណ១០ឆ្នាំមាតាបិតាបាននាំកុមារ**ញ៉ុក ថែម**ទៅសំណាក់នឹងព្រះគ្រូអាចារ្យ**សង** ត្រូវជាជីតានៅវត្តពោធិវាលសង្កាត់ស្រុកសង្កែខេត្របាត់ដំបងដើម្បីសិក្សាអក្សរភាសាជាតិនិងព្រះពុទ្ធសាសនា។

មួយឆ្នាំក្រោយមកព្រះគ្រូអាចារ្យ **សង** ទទួលអនិច្ចធម្ម។ ឪពុកកុមារ**ញ៉ុក ថែម**បាននាំឲ្យទៅសំណាក់រៀននឹងព្រះគ្រូ **អ៊ីវ ឌួត**។

លុះអាយុបាន១៥ឆ្នាំព្រះគ្រូ **អ៊ីវ ឌួត**បានបំបួសកុមារ**ញ៉ុក ថែម**ជាសាមណេរក្នុងសំណាក់លោកគ្រូអធិការ **សំ** ដែលជាចៅអធិការវត្តពោធិវាលក្នុងកាលនោះ។ តាំងពីពេលនោះមកសាមណេរបានសង្វាតរៀនសូត្រភាសាបាលីនិងធម្មវិន័យក្នុងសំណាក់អាចារ្យទាំងឡាយក្នុងវត្តពោធិវាលនេះ។

ក្នុងវេលាចប់សង្គ្រាមលោកទី១សាមណេរនេះបានទៅបន្តវិជ្ជាខាងព្រះពុទ្ធសាសនានៅក្រុងបាងកកប្រទេសថៃដោយធ្វើដំណើរតាមរទេះគោជាមួយឈ្មួញ។ អំឡុង១០ថ្ងៃបានទៅដល់ខេត្តសៀម១«បាចិនបុរី»។បន្ទាប់លោកបានចុះកប៉ាល់បន្តដំណើរ រួចឡើងរទេះភ្លើងនៅខេត្តប៉ៃរិវ ជិតប្រលប់ទើបដល់ទីក្រុងបាងកក។ ពួកឈ្មួញបាននាំសាមណេរ**ញ៉ុក ថែម**ទៅស្នាក់សិក្សារៀនសូត្រនៅវត្តព្រះកេតុនៅកុដិព្រះគ្រូព្រះ**មហាយ៉ៅ**ជាព្រះសង្ឃខ្មែរ១អង្គដែលគង់នៅថៃជាយូរឆ្នាំមកហើយ។

សាមណេរនេះឧស្សាហ៍ណាស់បានខំរៀនភាសាថៃវេយ្យាករណ៍និងធម្មវិន័យ។

ក្នុងឆ្នាំ១៩២១លោកបានប្រឡងជាប់សញ្ញាប័ត្រធម្មវិន័យថ្នាក់ត្រី។ ដល់លោកបានអាយុ២០ឆ្នាំនៅគ.ស.១៩២៣លោកបានប្រឡងជាប់ធម្មវិន័យថ្នាក់ទោ។

ដល់អាយុ២១ឆ្នាំលោកបានបំពេញឧបសម្បទជាភិក្ខុភាវៈក្នុងវត្តព្រះកេតុនេះឯងហើយនៅគ.ស.១៩២៩ ភិក្ខុញ៉ុកថែមបានប្រឡងជាប់ជាផ្លូវការនូវសញ្ញាប័ត្រមហាប្រាំប្រយោគ។

នៅថៃព្រះភិក្ខុអង្គនេះធ្លាប់បានធ្វើជាសាស្ត្រាចារ្យបង្រៀនបាលីនៅវត្តព្រះកេតុ, ធ្លាប់ធ្វើជាមេប្រយោគជាផ្លូវការកែវិញ្ញាណសារប្រឡងនៃសាមណៈនិស្សិត។ លោកធ្លាប់បានសរសេរបោះពុម្ពផ្សាយជា ភាសាថៃ -បាលី ដូចជា៖ នមោដីកាកថា, នានាជាតកវណ្ណន, ធម្មបទនិទ្ទេស, ទេវតាភាសិតនិងពុទ្ធភាសិត, អត្ថបទផ្សេងៗជាភាសាថៃបោះពុម្ពលើសាស្ត្រាស្លឹករឹត។

## ងារនិងតួនាទីផ្សេងៗ៖

ឆ្នាំ១៩៣០ភិក្ខុញ៉ុកថែមត្រឡប់មកស្រុកខ្មែរវិញបានធ្វើជាសមាជិកក្រុមជំនុំបកប្រែព្រះត្រៃបិដក។ នៅគ.ស.១៩៣៦ភិក្ខុអង្គនេះបានលាចាកសិក្ខាបទមកជាគ្រហស្ថ។

មួយឆ្នាំក្រោយមកលោកបណ្ឌិត**ញ៉ុកថែម**បានរៀបអាពាហ៍ពិពាហ៍ជាមួយនាង**ជួនណៃស៊ីម**នៅផ្សារឧដុង្គសង្កាត់រាំងចាស់ស្រុកឧដុង្គខេត្រកំពង់ស្ពឺ។ ក្រោយមកលោកមានបុត្រា៧នាក់និងបុត្រី៤នាក់។

លោកមានគោរម្យងារជា«ឃុននិពន្ធមន្ត្រី» ហើយនាវរាងគ.ស. ១៩៣៨ លោកបានធ្វើជានិពន្ធនាយកទស្សនាវដ្តី «កម្ពុជសុរិយា»ដែលចេញផ្សាយជារៀងរាល់ខែរហូតដល់ឆ្នាំ១៩៧៥។

ពីឆ្នាំ១៩៤៣ដល់១៩៤៦អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ (កញ្ញា**ស៊ុយស្ហានការប៉ឺឡែស** (Suzanne KARPELES) ក្រោយមកមាន**ព្យែរដុយប៉ុង**(Pierre DUPONT) យល់ថាលោកបណ្ឌិត**ញ៉ុកថែម**ជាអ្នកប្រាជ្ញស្ថាប័ននេះហើយបានតែងតាំងលោកជាតំណាងដើម្បីធ្វើកម្មវិធីសិក្សាពុទ្ធសាសនានិងសម្ភោធន៍អាគារពុទ្ធសាសនាផ្សេងៗនៅស្រុកលាវនិងស្រុកយៀកណាមខាងត្បូង។

គ.ស.១៩៤៥ លោក**អាឡេចសង្ឌ្រីយ** (Le général ALESSANDRI) ឧត្តមសេនីយការបារាំង តម្រូវឲ្យបណ្ឌិត**ញ៉ុកថែម**ធ្វើជាក្រុមការទូតសហរដ្ឋឥណ្ឌូចិនបារាំងសេសនៅព្រៃនគរ។ ពេលនោះលោកបានធ្វើជាអ្នកបកប្រែភាសា «ថៃ.បារាំង.ខ្មែរ« ក្នុងវិទ្យុនៃក្រុងនោះដើម្បីទាមទាញដែនដីបាត់ដំបងនិងសៀមរាបពីថៃ។

គ.ស.១៩៤៦លោកត្រឡប់មកភ្នំពេញវិញធ្វើការនៅពុទ្ធសាសនបណ្ឌិត្យនិងបង្រៀននៅវិទ្យាល័យស៊ីសុវត្ថិ។

គ.ស.១៩៥០ ក្រសួងអប់រំជាតិបានតែងតាំងបណ្ឌិត**ញ៉ុកថែម**ជាសាស្ត្រាចារ្យរហូតដល់ឆ្នាំ១៩៥៧ពេលបានចូលនិវត្តន៍។[1] តែក្រសួងអប់រំជាតិបានតែងតាំងលោកបន្តទៅទៀតជាសាស្ត្រាចារ្យឧត្តមសិក្សា

[1] នៅកម្ពុជាសម័យសង្គមរាស្ត្រនិយម មន្ត្រីរាជការខ្មែរជាទូទៅត្រូវចូលនិវត្តន៍នាពេលគម្រប់អាយុ៥៥ឆ្នាំ។

*កិត្តិយស* (Professeur honoraire)*នៃវិទ្យាស្ថានជាតិគរុកោសល្យ, មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ*[2] *ព្រមទាំងពុទ្ធកមហាវិទ្យាល័យ។*

*បណ្ឌិត*ញ៉ុកថែម*លោកជាសមាជិកក្រុមជំនុំវប្បធម៌តាំងពីឆ្នាំ១៩៤៧មកហើយៗលោកជាអ្នកផ្ដើមបង្កើតសមាគមអ្នកនិពន្ធខ្មែរក្នុងឆ្នាំ១៩៥៦ដោយសហការជាមួយលោក*ហ៊ែលសុំផា, *អ្នកស្រី*ស៊ុយហៀង, *លោក*លាងហាប់អាន, *លោក*លីធាមតេង *ជាដើម។ នៅដំបូងសាស្ត្រាចារ្យ*ញ៉ុកថែម*មានតួទីជាប្រធានបណ្ដោះអាសន្នគឺនៅក្នុងខែមករានិងកុម្ភៈ១៩៥៦ហើយក្នុងបញ្ជីសមាជិកសមាគមអ្នកនិពន្ធខ្មែរលេខ១ ក្នុងលេខបញ្ជី។*[3]

[2] *តាមការស្នើសុំរបស់សាស្ត្រាចារ្យ*កេងវ៉ាន់សាក់*ទៅក្រសួងអប់រំជាតិដោយយល់ថាបណ្ឌិត*ញ៉ុកថែម*ជាសាស្ត្រាចារ្យប្រកបដោយសមត្ថភាពខ្ពង់ខ្ពស់ក្នុងការផ្ទេរចំណេះដឹងផ្នែកវប្បធម៌អក្សរសាស្ត្របាលី និងខ្មែរទៅនិស្សិតសម័យនោះ (នេះសំដីផ្ទាល់របស់សាស្ត្រាចារ្យ*កេងវ៉ាន់សាក់*ដែលបានផ្ដល់ពត៌មាននេះមកខ្ញុំ ព្រោះកាលនោះលោកជានាយកវិទ្យាស្ថានជាតិគរុកោសល្យ)។ ក្រសួងសិក្សាធិការយល់តាមសំណើលោកនាយកវិទ្យាស្ថានជាតិគរុកោសល្យ ហើយក៏បានបន្តការងារលោកទៅទៀត។ នេះគឺជាករណីពិសេសមួយសម្រាប់ឧត្តមសិក្សាខ្មែរជូនចំពោះសាស្ត្រាចារ្យដែលមានសម្បទានិងមានវិជ្ជាទូទៅខ្ពង់ខ្ពស់។*

[3] *ជីវប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ សមាជិកសមាគម*(មានលំដាប់លេខចូលមុខ-ក្រោយ), *ផ្សាយដោយសមាគមអ្នកនិពន្ធខ្មែរឆ្នាំ១៩៧០ជាកំណាត់ទាញដោយម៉ាស៊ីនរូណេអូ* (Ronéo)។

នាខែធ្នូ១៩៦៦ លោកបានទទួលការតែងតាំងជាសមាជិកគណៈមេប្រយោគថ្នាក់បណ្ឌិតក្នុងការប្រឡងយកសញ្ញាប័ត្របណ្ឌិតអក្សរសាស្ត្រសម្តេចសង្ឃរាជ **ជួន ណាត**។[4]

លោកប្រហែលទទួលអនិច្ចកម្មនៅឆ្នាំ១៩៧៤[5]។លោកបានទទួលគ្រឿងឥស្សរិយយសជាសគុណបំណាច់ផ្សេងៗពីបរទេសនិងមាតុភូមិគឺ៖ ឥស្សរិយយសមុនីសារភរណ៍(១៩៤០), ឥស្សរិយយសប្រទេសលាវឈ្មោះអស្សរិទ្ធីក្រុងលួង, ឥស្សរិយយសឈ្មោះអស្សរិទ្ធីជ្រាកុងអណ្ណាម(១៩៤៣), មេដាយការងារប្រាក់ប្រទេសកម្ពុជា(១៩៦០), មេដាយអស្សរិទ្ធីនៃព្រះរាជាណាចក្រកម្ពុជា(១៩៦២)។

លោកបានទុកស្នាដៃច្រើនឲ្យបងប្អូនខ្មែរសិក្សាបន្តគឺមានទាំងផ្នែកធម៌ទាំងផ្នែកលោកិយហើយលោកជាអ្នកនិពន្ធសំខាន់នៃទស្សនាវដ្តីវប្បធម៌និងពុទ្ធសាសនាប្រចាំខែ«**កម្ពុជសុរិយា**«ដោយបានសរសេរពីអក្សរសាស្ត្រខ្មែរជាច្រើនលេខ[6]។

លោកបាននិពន្ធរឿងប្រលោមលោកសំខាន់២ដែលយើងរាល់គ្នាស្គាល់គឺ៖

---

[4] សូមអាន«កំណត់ហេតុ នៃការប្រជុំគណៈមេប្រយោគនៃបណ្ឌិតវិជ្ជាអក្សរសាស្ត្រចំពោះស្នាព្រះហស្តសម្តេចព្រះមហាសុមេធាធិបតី**ជួន ណាត** ជោតញ្ញាណោព្រះសង្ឃរាជ» ដែលមានបង្ហាញនូវឧបសម្ព័ន្ធ។

[5] តាមសេចក្តីសង្កេតជាមួយអ្នកស្គាល់លោកផ្ទាល់មានសាស្ត្រាចារ្យឡុចផៃ្វដ៍ជាដើម។

[6] យើងបានស្រង់ខ្លះៗចេញពីជីវប្រវត្តិលោក**ញ៉ុក ថែម**ចុះផ្សាយក្នុងទស្សនាវដ្តី«**កម្ពុជសុរិយា**», ១៩៦៩,លេខ២, ទំព័រ១៦៣ដល់១៨១។

១) *បិសាចស្នេហា*, ភ្នំពេញ, ព.ស.២៤៨៥ ត្រូវនឹងគ.ស.១៩៤១/១៩៤២, ៣៩ទំព័រ។

២) *កុលាបប៉ៃលិន*, ភ្នំពេញ, ១៩៤៣, ១៥២ទំព័រ (មានការបកប្រែជាភាសាបារាំង និង ជាភាសាសៀម (សូមមើលឧបសម្ព័ន្ធ)។

សក្ខីភាពទាំងនេះបង្ហាញឲ្យឃើញថា «សាស្ត្រាចារ្យ**ញ៉ុកថែម** ជាអ្នកប្រាជ្ញផ្នែកអក្សរសាស្ត្រខ្មែរនិងពុទ្ធសាសនាមួយរូបដែលប្រជាពលរដ្ឋបានស្គាល់សឹងតែគ្រប់ៗរូប។ លោកជាអតីតសាស្ត្រាចារ្យនៅពុទ្ធកមហាវិទ្យាល័យនិងជាអតីតសាស្ត្រាចារ្យអក្សរសាស្ត្រខ្មែរនៅវិទ្យាស្ថានជាតិគរុកោសល្យ ហើយនិងជាសាស្ត្រាចារ្យភាសាបាលី នៅមហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកជានិពន្ធនាយកយ៉ាងឆ្នើមក្នុងទស្សនាវដ្ដីវប្បធម៌និងពុទ្ធសាសនាប្រចាំខែ «**កម្ពុជសុរិយា**» របស់ពុទ្ធសាសនបណ្ឌិត្យ។»

## ស្នាដៃ សំខាន់ៗ៖

កាលលោកទៅសិក្សា និងធ្វើការនៅប្រទេសថៃលោក**ញ៉ុកថែម** បាននិពន្ធសៀវភៅជាភាសាថៃ ឬ បាលី-ថៃ។ ស្នាដៃទាំងនោះមានជាអាទិ៍៖ នមោកថា នានាជាតក វណ្ណនា ធម្មនិទ្ទេសភាគ១ ទេវតាភាសិត និងពុទ្ធភាសិត។[7]

ក្រៅពីនេះ លោកមានស្នាដៃជាភាសាខ្មែរយ៉ាងច្រើនដូច

[7] សូមអានបន្ថែមជីវប្រវត្តិសង្ខេបនៃអ្នកនិពន្ធ**ញ៉ុកថែម**ដោយអ្នកនិពន្ធផ្ទាល់ក្នុងសៀវភៅ*កុលាបប៉ៃលិន*, ភ្នំពេញ,សេងង្ហួនហួត, ១៩៦១, ទំព័រ កដល់ច។

ជា៖

- ពុទ្ធប្បវត្តិសង្ខេប
- វិជ្ជាប្រតិបត្តិធម៌, ភ្នំពេញ, រោងពុម្ព អាលប៊ែរពកតែ
- ចុឡវេទល្លសូត្ត (ប្រែ), ភ្នំពេញ, រោងពុម្ព អាលប៊ែរពកតែ
- អនុពុទ្ធប្បវត្តិ ភាគ១-២
- ប្រជុំភាសិត ភាគ១-២, ភ្នំពេញ, រោងពុម្ព អាលប៊ែរពកតែ
- មហាវេស្សន្តរជាតក, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ,
- ជាតិ សាសនា ព្រះមហាក្សត្រ
- រឿងបិសាចស្នេហា (ប្រលោមលោកបោះពុម្ពឆ្នាំ១៩៤២)
- រឿងកុលាបប៉ៃលិន (ប្រលោមលោកបោះពុម្ពលើកទី១ក្នុងរវាងឆ្នាំ១៩៤៣)។ រឿងនេះមានការបកប្រែជាភាសាបារាំងនិងជាភាសាសៀម ហើយបានយកទៅធ្វើជាខ្សែភាពយន្តទៀតផង (សូមមើលរូបនៅឧបសម្ព័ន្ធ)។
- ពន្លឺអាស៊ីទ្វីប (ប្រែ)
- បញ្ញាសជាតកសង្ខេប, ភ្នំពេញ, មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ, ១៩៦៣,៥៥៦ទំព័រ។
- បែបរៀនភាសាបាលីជាន់ដំបូង, ភ្នំពេញ, មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ, ១៩៦៤.១៩៦៥។

- បទានុក្រមបាលី, ភ្នំពេញ, រោងពុម្ពឧដុង្គមានជ័យ,១៩៦៦។[8]

សារុបសេចក្តីមកបានបង្ហាញថាសាស្ត្រាចារ្យញ៉ុកថែមបាន សរសេរអត្ថបទស្រាវជ្រាវជាច្រើនទៀតជាពិសេសគឺអត្ថបទ ស្រាវជ្រាវសំខាន់ៗដែលទាក់ទងនឹងការស្រាវជ្រាវក្នុងអក្សរ សិល្ប៍វិជ្ជាដូចជាៈ

-យោបល់និងការពន្យល់ខ្លះៗអំពីតាពងប្រវត្តិកាលនៃអក្សរ សាស្ត្រខ្មែរខ្លះ, ទស្សនាវដ្តីវិទ្យាស្ថានគរុកោសល្យ, លេខ២, ១៩៥៩, ទំព័រ២០ដល់២៩។

-ឯកសារសាស្ត្រាស្លឹករឹតនិងក្រាំងដែលមាននៅវិជ្ជាស្ថាននៃ ពុទ្ធសាសនបណ្ឌិត្យ, ទស្សនាវដ្តីកម្ពុជសុរិយា, ១៩៦៥ (៨) ទំព័រ៨១៦ដល់៨៣១, លេខ៩, ទំព័រ៩៥៧ដល់៩៦៨, លេខ ១១, ទំព័រ១១៦៣...ហើយនិងលេខ តៗទៅទៀត។ល។

---

[8] សូមមើល DIK KEAM, Secrétaire général Adjoint de l'Association des Ecrivains khmers, *Catalogue des auteurs khmers et étrangers*, Phnom Penh, 1966, p.18.សូមអានបន្ថែម ឃីងហុកឌី,*អក្សរសិល្ប៍ខ្មែរសតវត្សទី២០ ករីនិពន្ធនិងកម្រងអត្ថបទ*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០២។

# ឧបសម្ព័ន្ធ



Ph.Loch Phléng

រូបថត គរុសិស្ស ជំនាន់ទី២ នៅវិទ្យាស្ថានជាតិគរុកោសល្យ ភ្នំពេញ ១៩៥៩-១៩៦១។ នៅជួរទី១ សាស្ត្រាចារ្យកេងវ៉ាន់សាក់ អង្គុយទី១០ពីឆ្វេងទៅស្តាំនៅជិតភរិយាលោកអ្នកស្រី ស៊ុយស្ហាន ស្លៀកសំពត់ ផ្កា នៅជិត Claude Biessy ស្លៀកខោអាវពណ៌ស ហើយនៅជិតលោកម្ខាងទៀតគឺ លោកសុនសេន ជាអនុប្រធានវិទ្យាស្ថាននេះ។សាស្ត្រាចារ្យញ៉ុកថែម អង្គុយជិត Prof. Boussineau នៅខាងស្តាំដៃ (ដែលមានពុកមាត់និងពុកចង្កាវែង)ហើយនៅឆ្វេងដៃលោកគឺអ្នកគ្រូជីគីមអាន។ (រូបថត របស់សាស្ត្រាចារ្យ ឡុចផ្លែង, ១៩៥៩).លោកឡុងសៀមឈរក្រោយបង្អស់ ទី៤ពីឆ្វេងទៅស្តាំ។ លោកឡុចផ្លែងឈរក្រោយបង្អស់ ទី១២ពីឆ្វេងទៅស្តាំ។




Ph. Loch Phléng

នាមបុគ្គលិកសិក្សាទាំងនេះដឹងដោយលោកគ្រូម៉ក់គឹននិងលោកគ្រូឡុចផ្លេង៖

-* 1er rang assis de gauche à droite : 1. Mme Ngèt Phun (frs), 2.Mme Ouy Po Ho (frs), 3. Mme ?, 4.M. Yos Man, 5. Vén. Thach Prang (prof. pali), 6. Prof. Khiev Komar, 7. M.?, 8. Prof. Claude Biessy, 9. Mme Prof. Suzanne Keng Vannsak, 10 . Prof. Keng Vannsak, 11. Prof. Son Sèn, 12. Mme Frse. Prof.?, 13. Prof. Boussineau, 14. **Prof. Nhok Thèm**, 15. Mme Chi Kim An.

-* 2ème rang debout de gauche à droite : 16.M. ?, 17. M. ?, 18.M.Touch To Sa, 19 M. Thach Chov, 20. M. Samreth Bo, 21. M. Kim Son Trinh, 22. M. Mok Mao, 23. M. Layr Kim Séng, 24. M.Leang Sun( hist-géo), 25. M.?, 26. M.?, 27.M.?, 28. M. Sakhân?, 29. M. Ing Thân, 29. M. Som Nau, 30. M. Ngau Va, 31. M. Chhit Sri, 32. M. ?, 33. M. Loek Rasi.

-* 3ème rang debout de gauche à droite : 34. M. ?, 35. M. ?, 36. M. ?, 37. M. Ul Chan, 38. You Sam Bo, 39. M. Chuon Vang, 40. M. Saing Rin, 41. M. ?, 42. M. ?, 43. M. Pèn Pé Né, 44. M. ?, 45. M.?, 46. M. ?, 47. M. Chhay Boun Chorn, 48. M. Toeng Chhan, 49. M. Chea Chhean, 50. M. ?, 51. M.?, 52. M. Nhep Mao.

-*4ème rang debout de gauche à droite: 53. M. Kov Sun, 54. M. ?, 55. M. Ly Yam, **56. Long Seam**, 57. M. ?, 58. M. Kov Toek Hieng, 59. M. Chhiev Chrien, 60. M. ?, 61. M. Ros Pin, 62. M.?, 63. M. Lon Kéng, 64. M. **Loch Phléng**, 65. M. Suon Soun Maly, 66. Ouk Samân, 67. M. Var Sim Samreth, 68. M. ?, 69. M. ?, 70. Yim Santhor (physique-chimie), 71. M. Som Hol, 72. M. Chim Sunly.

# កំណត់ហេតុ

## នៃការប្រជុំរបស់គណៈមេប្រយោគ នៃបណ្ឌិតវិជ្ជាអក្សរសាស្ត្រ ចំពោះស្នាព្រះហស្ត សម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត ជោតញ្ញាណោ ព្រះសង្ឃរាជ

ឆ្នាំមួយពាន់ប្រាំបួនរយហុកសិបប្រាំពីរ ខែមេសា ថ្ងៃទីប្រាំពីរ ម៉ោងប្រាំបី នៅសាកលវិទ្យារិការដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទ គណៈមេប្រយោគដែលបានត្រូវតែងតាំងឡើង ដោយអនុលោមតាមព្រះរាជយោបល់ដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាសិក្សាធិការជាតិ ដោយសេចក្តីសម្រេចនៃសាកលវិទ្យាធិការ លេខ ៤.៦១៩ ស.ស.ក. ចុះថ្ងៃទី ៩ ធ្នូ ឆ្នាំ ១៩៦៦ បានប្រជុំគ្នាជាលើកក្រោយបំផុត ដើម្បីពិភាក្សាអំពីទស្សនកថា ឬ និក្ខេបបទ សម្រាប់បណ្ឌិតវិជ្ជាអក្សរសាស្ត្រ ចំពោះស្នាព្រះហស្តសម្តេចព្រះមហាសុមេធាធិបតី ជួន - ណាត ជោតញ្ញាណោ ព្រះសង្ឃរាជ ។

បានមកកាន់ទីប្រជុំនោះ :

- សហជីវិន គីង - គុន សាកលវិទ្យាធិការ ...................................... ប្រធាន
- សហជីវិន ង្វៀង - សារិន ព្រឹទ្ធសាស្ត្រាចារ្យនៃមហាវិទ្យាល័យ អក្សរសាស្ត្រ និងមនុស្សសាស្ត្រ ...................................... សមាជិក
- សហជីវិន កេង - វ៉ាន់សាក់ សាស្ត្រាចារ្យនៅមហាវិទ្យាល័យ អក្សរសាស្ត្រ និងមនុស្សសាស្ត្រ ...................................... សមាជិក
- សហជីវិន ញ៉ុក - ថែម សាស្ត្រាចារ្យនៅមហាវិទ្យាល័យ អក្សរសាស្ត្រ និងមនុស្សសាស្ត្រ ...................................... សមាជិក

គណៈមេប្រយោគខាងលើនេះ បានពិនិត្យដោយហ្មត់ចត់ នូវស្នាព្រះហស្តទាំងឡាយរបស់សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ កាលពីពេលមុនរួចទៅហើយ ទើបយកការពិនិត្យនោះមកពិភាក្សាគ្នាអស់ចិរវេលាដ៏យូរ ក៏បានសម្រេចជាឯកច្ឆន្ទដូចតទៅនេះ :

ក្រៅអំពីអត្ថបទផ្នែកសាសនា ដែលមានសារៈជ្រាលជ្រៅផុតហួសសមត្ថភាពសមាជិកគណៈមេប្រយោគនេះទៅទៀត ហើយដែលជាស្នាព្រះហស្តមួយផ្នែកយ៉ាងសំខាន់ គាបបង្ហាញចំណេះវិជ្ជានិងប្រាជ្ញាទូលំទូលាយក្រៃលែងរបស់សម្តេចព្រះសង្ឃរាជ នៅមានស្នាព្រះហស្តជាអត្ថបទអក្សរសាស្ត្រថែមទៀតផង ពិសេសជាងគេគឺ :

- វចនានុក្រមខ្មែរ
- ហើយនិងកច្ចាយនូបត្ថម្ភកៈ ដែលជាវេយ្យាករណ៍បាលី សរសេរនិងពន្យល់ជាភាសាខ្មែរៗ

អត្ថបទទាំងពីរនេះ មិនត្រឹមតែមានលក្ខណៈជាស្នាដៃឃ្លាំងវិជ្ជាប៉ុណ្ណោះទេ ថែមទាំងមានលក្ខណៈជា ទស្សនកថា ឬ និក្ខេបបទពិតប្រាកដ ព្រោះថាជាការតែងនិពន្ធ ដែលបិតនៅលើការបញ្ជាក់ទស្សនៈមួយដ៏សំខាន់ ។

ទស្សនកថានៅក្នុងវចនានុក្រមខ្មែរ គឺសេចក្តីបញ្ជាក់ទស្សនៈ ជាតិសព្ទនិយម ដែលសរសេរនិងពន្យល់ពាក្យដោយគោរព ជាតិសព្ទ ជាតិកំណើត របស់ពាក្យ ។

ក្នុងកច្ចាយនូបត្ថម្ភកៈ ដែលជាវេយ្យាករណ៍បាលី សរសេរនិងពន្យល់ជាភាសាខ្មែរ ទស្សនកថាជ្រាលជ្រៅ គឺសេចក្តីបញ្ជាក់ទស្សនមូលដ្ឋាន ដែលនិយមថាភាសាខ្មែរមានសមត្ថភាព អាចយកវិជ្ជាដ៏ពិបាកមកអធិប្បាយ សិក្សាបានដោយច្បាស់លាស់ ។

យ៉ាងណាមិញ សម្តេចព្រះសង្ឃរាជ ទ្រង់បានចាប់ផ្តើមជំហ៊ានបន្តស់ យកមុខវិជ្ជាមួយផ្នែកដែលយើងធ្លាប់ទទួលថាជាវិជ្ជាពិបាក ពោលគឺភាសាបាលី មកតែងនិពន្ធ ពន្យល់ បង្រៀនជាភាសាជាតិឲ្យបានសុះសាយទូទៅ ឆាប់យល់និងឆាប់ចេះ ។

ស្នាព្រះហស្តដែលអាចយកភាសាខ្មែរ មកប្រើឲ្យបានសម្រេចជោគជ័យបែបនេះបាន គឺពិតជាទស្សនកថាសំខាន់ណាស់ ចំពោះការសិក្សាជាភាសាបរទេស ឬមួយជាភាសាជាតិ ពិសេសគឺចំពោះវិជ្ជាបាលី ដែលដើមឡើយ គេធ្លាប់តែទៅស្វែងរៀនឯបរទេស ឬរៀនជាភាសាបរទេសសុទ្ធៗ ។

ជោគជ័យក្នុងការប្រើភាសាខ្មែរនេះ បានបំបាត់ទស្សនៈមួយ ដែលធ្លាប់ស្មានថាភាសាជាតិ ពុំអាចបណ្តុះបំណេះចេះដឹងបានឡើយ ។

កច្ចាយនូបត្ថម្ភកៈនេះ បញ្ជាក់តាមទ្រឹស្តីផង និងតាមការអនុវត្តផង ថាភាសាខ្មែរពុំមែនទ្រុឌទ្រោមដូចទម្លាប់ធ្លាប់ស្មាននោះទេ តែជាភាសារបស់ជនជាតិ អ្នកមានអរិយធម៌ធ្លាប់រុងរឿង បានបញ្ចាំងការប្រែប្រួលខ្ពង់ខ្ពស់រួចទៅហើយ ហើយជាភាសាមានសមត្ថភាពចម្រើន អាចបណ្តុះបញ្ញា និងវិជ្ជាតទៅទៀតបាន ។

ភាសាខ្មែរប្រើបានត្រឹមត្រូវ គឺអាស្រ័យនៅលើវចនានុក្រមខ្មែរនោះដែរ ។

តើវចនានុក្រមនឹងអាងលើគោលអ្វី ដើម្បីពន្យល់និងសរសេរពាក្យឲ្យមានឯកភាព របៀបរៀបរយ សមហេតុ សមផល ទៅតាមភាសាជាតិ ?

បញ្ហានេះវចនានុក្រមខ្មែរ បានដោះស្រាយដោយអាងលើទស្សនៈ ជាតិសព្ទនិយម ដែលពន្យល់សរសេរ ហើយនិងអានពាក្យតាមតួអក្សរជាតិ ប្រភពដើមរបស់ពាក្យ ។

គោលលំនាំនេះ បានបង្កើតអក្សរ ជាតិសព្ទ ដែលតម្រូវឲ្យពាក្យណាមានជាតិជាខ្មែរសុទ្ធ ត្រូវសរសេរជាមួយនឹងអក្សរដើមកំណើតតាមវិធីបែបខ្មែរ ។ ចំណែកឯពាក្យមានជាតិ ប្រភព សំស្ក្រឹត បាលីវិញ ត្រូវសរសេរជាមួយនឹងតួអក្សរដើមកំណើតតាមវិធីបែបសំស្ក្រឹត - បាលី ។

ទស្សនៈគោរពជាតិសព្ទ ផ្ទុយគ្នានឹងសូរសព្ទនិយម ដែលយកសូរសំឡេងធ្វើជាធំ : សូរយ៉ាងណា សរសេរយ៉ាងនោះ ។ អក្សរសរសេរតាមសំឡេងអាន ឬនិយាយ ជាអក្សរសូរសព្ទ ។

កាលមុនសម័យវចនានុក្រមខ្មែរ អក្សរខ្មែរបានប្រើលាយចម្រុះគ្នា នូវអក្សរសូរសព្ទផង និងអក្សរជាតិសព្ទផង ប៉ុន្តែពុំសមហេតុ សមផលទេ ពីព្រោះជួនកាលក៏ជាអក្សរសូរសព្ទខ្លាំងពេក នាំឲ្យបាត់បង់ប្រភពពាក្យ ឬជួនកាលក៏ជាអក្សរជាតិសព្ទហួសហេតុ នាំឲ្យពាក្យខ្មែរប្រែទៅជាពាក្យបរទេសវិញ ។

នៅក្នុងបរិយាកាសភក់ពយបែបនេះ វចនានុក្រមខ្មែរ "ថ្វីព្រះហស្តសម្តេចព្រះសង្ឃរាជ" បានរៀបអក្សរខ្មែរជារបៀប សង្កត់លើគោលជាតិសព្ទនិយម ដែលទ្រទ្រង់ឯកភាព នៃអក្ខរាវិធីខ្មែរសព្វថ្ងៃនេះឯង ។

ឯអក្ខរាវិធីគោរពជាតិសព្ទ ប្រភពខ្មែរ ឬប្រភពសំស្ក្រឹត - បាលី បែបនេះ បានធ្វើឲ្យវចនានុក្រមខ្មែរ មានសភាពជាតាកងយ៉ាងធំបង្ហាញពាក្យបរទេស ហើយនិងពាក្យខ្មែរ ដូចនេះ គឺមានលក្ខណៈជាទស្សនកថាពន្យល់អំពីប្រភព ហើយនិងតម្លៃនៃអារ្យធម៌ខ្មែរថែមទៀតផង ។

គឺការបេះបញ្ជាក់ទស្សនមូលដ្ឋានឲ្យទៅជាការអនុវត្ត បង្កើតឯកភាពក្បួនវិធីភាសា ដើម្បីយកភាសារៀបរយនេះទៅប្រើអធិប្បាយវិជ្ជាបែបដូច្នេះហើយ ដែលជាហេតុនាំឲ្យស្នាព្រះហស្តសម្តេចព្រះសង្ឃរាជ មានលក្ខណៈជាទស្សនកថា ពិតប្រាកដ សម្រាប់បណ្ឌិតវិជ្ជាអក្សរសាស្ត្រ ។

ប៉ុន្តែទស្សនកថានៅក្នុងវចនានុក្រមខ្មែរ ហើយនិងកច្ចាយនូបត្ថម្ភកៈទាំងពីរនេះ ពុំមែនជាថ់

ចេញទីទៃពីគ្នាទេ ផ្ទុយទៅវិញ អាចរួមគ្នាជាទស្សនគតិធំមួយដែលបានបញ្ជាក់ថា ភាសាខ្មែរគឺពិតជាគ្រឿងប្រដាប់បញ្ញា អាចអធិប្បាយវិជ្ជាបានតាមក្បួនវិធីច្បាស់លាស់ ។

តម្លៃសំខាន់បំផុតឋិតនៅលើចំណុចដែលទស្សនគតិដ៏ធំសម្បើមនេះ ពុំមែនត្រឹមតែជាសេចក្តីបញ្ជាក់តាមផ្លូវទ្រឹស្តីប៉ុណ្ណោះទេ ថែមទាំងជាការបញ្ជាក់តាមផ្លូវអនុវត្តប្រាកដជាក់ស្តែង ធ្វើឲ្យអត្ថបទអក្សរសាស្ត្រថ្មីព្រះហស្តទាំងពីរនេះ មានសារៈជាគម្ពីរឯកសារមូលដ្ឋានសម្រាប់ប្រើភាសាជាតិ ព្រមទាំងជាពន្លឺជួយបំភ្លឺវប្បធម៌ អារ្យធម៌ខ្មែរ ឲ្យភ្ញាក់ស្មារតីចំពោះសភាព និងតម្លៃពិសេសរបស់ខ្លួនទៀតផង ។

អាស្រ័យហេតុផលទាំងប៉ុន្មានខាងលើនេះ គណៈមេប្រយោគដែលបានតែងតាំងឡើងតាមព្រះរាជបញ្ញាដ៏ខ្ពង់ខ្ពស់ នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ បានមូលមាត់ទទួលជាឯកច្ឆន្ទថា :

"ស្នាព្រះហស្តសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ ក្នុងផ្នែកអក្សរសាស្ត្រមានលក្ខណៈពិតប្រាកដ ហើយនិងតម្លៃលើសលុប ជាទស្សនគតិបណ្ឌិតវិជ្ជាអក្សរសាស្ត្រ ។

ដូច្នេះ សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ **ជួន-ណាត** ជោតញ្ញាណោ មានគុណធម៌ពេញលក្ខណៈជា **មហាបណ្ឌិតវិជ្ជាអក្សរសាស្ត្រ** ។

គណៈមេប្រយោគ សូមថ្លែងសេចក្តីសរសើរដ៏ក្រៃលែង ចំពោះព្រះមហាបណ្ឌិតអក្សរសាស្ត្រខ្មែរ ជាដំបូងបង្អស់នេះ ហើយសូមថ្លែងដ៏ទឡ្ហារិកថា :

វប្បធម៌ខ្មែរអាចមានជោគជ័យបែបនេះបាន ក៏ដោយសារព្រះរាជនយោបាយ សម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ។ ព្រះអង្គបានទាមទារឯករាជ្យជាតិបានហើយ ក៏ទ្រង់បានកសាងជាតិគ្រប់វិស័យ ដើម្បីលើកតម្កើងវប្បធម៌ អារ្យធម៌ ហើយនិងកិត្តិយសខ្មែរឲ្យបានរុងរឿងតាមតំណដំណែល ដ៏ល្បីល្បាញនៃព្រះរាជបល្ល័ង្ក ក្នុងប្រវត្តិសាស្ត្រខ្មែរ ។

ធ្វើនៅសាកលវិទ្យាធិការដ្ឋាននៃសាកលវិទ្យាល័យភូមិន្ទ

ក្រុងភ្នំពេញ, នៅថ្ងៃទី ៧ មេសា ១៩៦៧

ប្រធាន

សមាជិក

៣៩៦

*ខាងលើនេះជាសម្រង់ចេញពី សៀវភៅបទសម្ភាសន៍នាទីអក្សរសាស្ត្រសម្តចព្រះសង្ឃរាជ ជួនណាត, ផ្សាយដោយវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិតសភាកម្ពុជា, ២០០២។*



លោក ញ៉ុក ថែម

## លោក ញ៉ុក ថែម (១៩០៣-១៩៧៤)

ញ៉ុក ថែម គឺជាអ្នកនិពន្ធដែលបានបន្សល់ទុកនូវស្នាដៃយ៉ាងច្រើន ពិសេសនោះគឺប្រលោមលោករឿងកូលាបប៉ៃលិន និងថែមទាំងបានចុះផ្សាយអត្ថបទមួយចំនួនធំក្នុងកម្ពុជសុរិយាផងដែរ។ ដោយលោកមានចំណេះដឹងច្រើន ទាំងអក្សរសាស្ត្រជាតិ និងភាសាបរទេស លោក ញ៉ុក ថែម បានបំពេញនាទីសំខាន់ៗជាច្រើនក្នុងការរៀបចំព្រះត្រៃបិដក ក៏ដូចជាអភិវឌ្ឍនភាពនៃវិស័យអក្សរសាស្ត្រជាតិ។ ពេលមានអាយុ១៦ឆ្នាំ លោកបានបន្តវិជ្ជាព្រះពុទ្ធសាសនានៅបាងកករហូតដល់ឆ្នាំ១៩៣០ បានត្រឡប់មកមាតុភូមិវិញ និងបានចូលបំរើការងារនៅក្រុមជំនុំបកប្រែព្រះត្រៃបិដកក្រោមអធិបតីព្រះធម្មលិខិត ល្វី ឯម។ លោកបាន ក្លាយជានិពន្ធនាយកទស្សនាវដ្ដីកម្ពុជសុរិយានៅព្រះរាជបណ្ណាល័យក្នុងឆ្នាំ១៩៣៨។

ដើមខែកុម្ភៈ ឆ្នាំ១៩៣៩ រាជការបានចាត់ឱ្យធ្វើព្រះរាជតំណាងសម្ដេចព្រះរាជអយ្យកោនរោត្តម សុធារស ព្រះអធិបតីនៃពុទ្ធសាសនបណ្ឌិត្យកម្ពុជា។ ឆ្នាំ១៩៤៣ លោកធ្វើជាតំណាងឱ្យអគ្គលេខាធិការ ព្សៃរ ឌុយប៉ង់តឺ ដើម្បីរៀបចំកម្មវិធីសិក្សាភាសាបាលី និងរៀបចំបង្កើតពុទ្ធសាសនបណ្ឌិត្យនៅខេត្តប៉ាក់សេប្រទេសលាវ។ ឆ្នាំបន្ទាប់មក លោកបានទទួលនាទីជាអ្នកការទូតប្រចាំសហភាពឥណ្ឌូចិន ក្នុងឋានៈជាអ្នកបកប្រែផ្សព្វផ្សាយតាមវិទ្យុពីភាសាបារាំង មកភាសាថៃ និងខ្មែរ។

ខែមករា ឆ្នាំ១៩៤៧ ក្រសួងអប់រំជាតិបានតែងតាំងលោកជាសមាជិកនៃគណៈកម្មការវប្បធម៌ ហើយលោកបានសុំលាឈប់ពីពុទ្ធសាសនបណ្ឌិត្យនៅចុងឆ្នាំ១៩៤៩។ បន្ទាប់ពីនោះមក លោក ញ៉ុក ថែម បានបន្តធ្វើជាសាស្ត្រាចារ្យជាប់កិច្ចសន្យារហូតដល់ឆ្នាំ១៩៥៦។ លោកក៏ជាស្ថាបនិកមួយរូបនៃសមាគមអ្នកនិពន្ធខ្មែរដែលបានបង្កើតឡើងក្នុងឆ្នាំ១៩៥៥។ ក្នុងចន្លោះឆ្នាំ១៩៥៦-១៩៥៧ លោកផ្លាស់ទៅធ្វើការនៅវិទ្យាល័យព្រះមុនីវង្សនាក្រុងបាត់ដំបង ប៉ុន្តែនៅឆ្នាំ១៩៥៨ត្រូវត្រឡប់មកធ្វើការនៅវិទ្យាស្ថានជាតិគរុកោសល្យ តាមសេចក្ដីស្នើរសុំពីក្រសួងអប់រំជាតិវិញ។

*ស្រង់ពីសៀវភៅ «ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត, ២០០៥, ទំព័រ៥២ (កែសម្រួលដោយ ផេននី អែដវីដស៍)។*




ក្រុមអភិបាលទី៧នៃសមាគមអ្នកនិពន្ធខ្មែរ។


ឃុន និពន្ធមន្ត្រី (ញ៉ុក-ថែម)

និពន្ធបណ្ឌិត នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ

# បិសាចស្នេហា

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ បានអនុញ្ញាតបោះពុម្ព

បោះពុម្ពលើកទី ១



ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៤៨៥

*ប្រលោមលោកបិសាចស្នេហា, ភ្នំពេញ, ពុទសាសនបណ្ឌិត្យ, ពស ២៤៨៥។*




*ប្រលោមលោក កុលាបប៉ៃលិន, ភ្នំពេញ, សេងងួនហួត, ១៩៦១។*

,




*បញ្ញាសជាតកសង្ខេប, ភ្នំពេញ, មហាវិទ្យាល័យអក្សរសាស្ត្រនិងមនុស្សសាស្ត្រ, ១៩៦៣,៥៥៦ទំព័រ។*



# មហាវេស្សន្តរជាតក

ចម្លងរៀបរៀងចេញពីគម្ពីរស្លឹករឹត

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រៀបរៀងផ្ទៀងផ្ទាត់

[illegible] និងសម្តេចសង្ឃនាយកទាំងពីរគណៈបានអនុញ្ញាតហើយ

បោះពុម្ពលើកទី ៩

ចំនួន ២.៥០០ ច្បាប់

ភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព.ស. ២៥១៣

មហាវេស្សន្តរជាតក, ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ,១៩៦៩, ៤៨០ទំព័រ (បោះផ្សាយលើកទី៩)។




រឿងកុលាបប៉ៃលិនប្រែជាភាសាបារាំងផ្សាយនៅប៉ារីសឆ្នាំ១៩៩៥, ៧៧ទំព័រ




រឿងកុលាបបៃលិនប្រែជាភាសាសៀម យកទៅបង្រៀននិស្សិតរៀនភាសាខ្មែរនៅសាកល
វិទ្យាល័យសិល្បករ នាក្រុងបាងកក, ព.ស ២៥៤០, ១៧២ទំព័រ។




ឆាយសុខ, សិក្សាកថាអត្ថបទរឿងកុលាបប៉ៃលិន, ភ្នំពេញ, ១៩៩៣/១៩៩៤, ២៦ទំព័រ។




រឿងកុលាបបៃលិនជាខ្សែភាពយន្តដែលមានតួឯកស្ត្រីគឺអ្នកស្រីឌីសាវែត។

វិជ្ជាសារ កម្ពុជសុរិយា, INP, ៣-៤, 1959: 20-29

**Étude de M. NHOK THEM sur la littérature khmère**

# យោបល់និងការពន្យល់ខ្លះ ៗ អំពីតារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរខ្លះ

ការស្រាវជ្រាវរកដើមកំណើតរឿង តាមអ្នកនិពន្ធរឿងឬប្រភពនៃរឿង ព្រមទាំងកាលបរិច្ឆេទនៃរឿងរ៉ាវផ្សេង ៗ ខាងផ្នែកអក្សរសាស្ត្រខ្មែរយើង ក្នុងអតីតកាលនោះមិនមែនជាការងាយស្រួលឡើយ ទោះបីជារឿងដែលគេបានដាក់សៀវភៅក្ដី ទោះបីគេកត់ត្រាទុកក្នុងក្រាំងឬសៀវភៅក្ដី យើងមិនសូវប្រទះឃើញឈ្មោះអ្នកនិពន្ធរឿង កាលបរិច្ឆេទនិងជីវប្រវត្តិពិតប្រាកដទេ គេច្រើនតែប្រទះឃើញឈ្មោះអ្នកកត់ត្រាចំឡង ឬអ្នកបានចំឡងទៅវិញ ។

អ្នកតនិពន្ធក្ដី អ្នកនិពន្ធរឿងល្បែង (សាស្ត្រល្បែងផ្សេង ៗ ) ក្ដី អ្នកនិពន្ធច្បាប់សីលធម៌ក្ដី អ្នកនិពន្ធរឿងផ្សេង ៗ ទៀតក្ដី ក្នុងសម័យបុរាណតាមដោយស្មានមិនមែនជាអ្នកឥតគំនិតដល់ទៅភ្លេចដាក់ឈ្មោះខ្លួន ឬ កាលបរិច្ឆេទភ្ជាប់ជាមួយនឹងរឿងនោះ ៗ ទេ ។ ប្រសិនបើខ្លួនជាភ្លេច ឬមិនចង់ដាក់ឈ្មោះខ្លួន កាលបរិច្ឆេទ ក្នុងរឿងនោះ ៗ ក៏គង់មានខ្លះដែរ ប៉ុន្តែប្រហែលជាមានភាគតិចទេ ។

យើងយល់ថា អ្នកនិពន្ធជាន់ដើមមិនមែនជាអ្នកកំណាញ់ឈ្មោះ-សករាជ ឬកាលបរិច្ឆេទទេ ប៉ុន្តែឈ្មោះសករាជ ឬ កាលបរិច្ឆេទ រលាយបាត់សាបសូន្យទៅអំពីរឿងនោះ ៗ ដោយអ្នកបានចំឡងតៗគ្នាមក គឺ មានអ្នកបានចំឡងខ្លះ បានលុបឈ្មោះនិងកាលបរិច្ឆេទរបស់អ្នកនិពន្ធចេញទៅ ហើយដាក់ឈ្មោះខ្លួននឹងសករាជនៅពេលបានចំឡងជំនួសវិញ ។ អ្នកបានចំឡងលើកទីពីរតមកទៀតក៏ធ្វើតាមទំនងអ្នកមុនដែរ ហើយអ្នកបានចំឡងឬសរសេរចំឡងត ៗ មកទៀត ក៏ប្រើវិធានការដូចគ្នាទៀត ។ ម្ល៉ោះហើយរឿងចាស់ ៗ ទាំងអម្បាលម៉ាណ ក៏ប្រែក្លាយទៅជារឿងទើបកើតឡើងជាន់ក្រោយអស់ទៅ ។ បើខ្លួនជាមានកែពាក្យពេចន៍ សំនួនវោហារឬអត្ថបទខ្លះផង នឹងធ្វើឲ្យរឿងនោះឃ្លាតឆ្ងាយអំពីច្បាប់ដើម កាន់តែច្រើនណាស់ទៅទៀត ( ត្រង់នេះយើងសូមអភ័យទោសចំពោះអ្នកបានចំឡងដោយសុទ្ធចិត្តឥតបេតនាក្លែងបំបាត់នាមអ្នកនិពន្ធនឹងកាលបរិច្ឆេទរបស់គេ ) ។



មានករីនិពន្ធខ្លះនៅក្នុងសតវត្សរ៍ទី ១៨ និងខាងដើមសតវត្សរ៍ទី ១៩ នៃគ្រិស្តសករាជ លោកអស់នោះមានមនោគ្គបាយភាពទុក ទូវក្ដីឈ្មោះកាលបរិច្ឆេទ-ជីវប្រវត្តិរបស់លោកក្នុងអត្ថបទផ្ដើមរឿង ឬអត្ថបទបញ្ចប់រឿង ។

រឿងណាមួយដែលអ្នកករីនិពន្ធបានធ្វើទុកដូច្នេះ ទើបមាននាមអ្នកករីនិពន្ធ នឹងកាលបរិច្ឆេទជាប់នៅក្នុងរឿងនោះ ៗ រហូតមកដល់សព្វថ្ងៃនេះ ។

**ឧទាហរណ៍ ៖** រឿងភោគកុលកុមាររបស់ឧកញ៉ាព្រះឃ្លាំង (ឯង), លោកន័យជាតករបស់ឧកញ៉ាវង្សាក្សត្រី (ឯង), ក្រុងសុភមិត្ររបស់ឧកញ៉ាកោសាធិបតី(កែប) វរនុជវរនេត្រ របស់ឧកញ៉ាចៅហ្វាយឃ្លាំង (មៀច), រឿងកាកីព្រះរាជនិពន្ធព្រះបាទអង្គដួង ។ល។

**បំពោះរឿង កាកី** សម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះបាទអង្គដួង ទ្រង់បាននិពន្ធព្រះរាជសារអ្នកបានរបស់ព្រះអង្គទុកក្នុងអត្ថបទផ្ដើមរឿងកាកី ដោយទ្រង់បានបញ្ជាក់សករាជទុកដល់៣យ៉ាង គឺពុទ្ធសករាជមហាសករាជនិងចុល្លសករាជព្រមទាំងថ្ងៃខែ ឆ្នាំពេលវេលាដែលទ្រង់បានចាប់ផ្ដើមនិពន្ធរឿងនេះ ។ ក្រៅអំពីនេះទ្រង់បានបញ្ជាក់ទីកន្លែង និងប្រភពនៃរឿងនេះផង ។

អ្នកករីនិពន្ធខ្លះ ប្រើវិធីបញ្ជាក់កាលបរិច្ឆេទជាពាក្យបាលី-សំស្ក្រឹត-ខ្មែរលាយចម្រុះគ្នាក៏មានដូចអត្ថបទផ្ដើមរឿងក្នុងលោកន័យជាតកថា: ‹‹សករាជចូលមក ឯកស័ព្ទឯកឆ សកខាល

ចំហុត ប្រាំដណ្ដប់កេច រនោចការពុធ ខែភទ្របទ(១) ស័កសម្រឹទ្ធិ ។ ត្រង់ពាក្យ "សករាជ" គឺមហាសករាជ ។ "ឯកស័ប្តឯកធ" គឺឯកៈ ១ ស័ប្តៈ ៧ ឯកៈ ១ ធៈ ៦= ១៧១៦ ។ "ស័កខាលចំហុត ប្រាំដណ្ដប់កេច រនោចការពុធ ខែភទ្របទ ស័កសម្រឹទ្ធិ" ។ (គឺថ្ងៃពុធ ១៥ កេច ខែភទ្របទ ឆ្នាំខាលសម្រឹទ្ធិស័ក) ។

អ្នកនិពន្ធខ្លះប្រើវិធីបញ្ជាក់កាលបរិច្ឆេទជាពាក្យបាលីសំស្ក្រឹតស្ទើរតែទាំងអស់ក៏មាន ដូចក្នុងអត្ថបទផ្ដើមរឿងនៃរឿងកោកកុលកុមារថា="មហាសករាជកាប់ កូលផាងឯកស័ប្ត-ទោធសពា ផុតចូលវស្សន្ត សាវ័ណមាសា ភុម្មពារ បុណ្ណមិយំ ។ នាមោមយា នឹងនាមជាតិជា ខក-ញាព្រះឃ្លាំង គន់គិតកាព្យកិច្ច ពាក្យពេចន៍ទុកតាំង ជាក្ដើតំណតាំង តំណសាស្ត្រា ។" (ត្រង់ពាក្យ= "ឯកស័ប្ត ទោធសពា" = មហាសករាជ ១៧២៦ ។ « ផុតចូលវស្សន្ត សាវ័ណ-មាសា ភុម្មពារ បុណ្ណមិយំ » = គឺថ្ងៃអង្គារ ១៥ កើតខែស្រាពណ៍ ឆ្នាំផុតក្នុងវស្សានរដូវ។ «នា-មោមយា » នាមរបស់ខ្ញុំ ··· ។

ប្រសិនបើយើងស្រាវជ្រាវពិនិត្យមើលដល់ទៅសិលាចារឹកទាំងឡាយគតោះទៀត នឹង-ឃើញថាស្ទើរតែគ្រប់ផ្ទាំងសិលាចារឹក ច្រើនតែឃើញមានបញ្ជាក់សករាជ ឬកាលបរិច្ឆេទដែលគេបានចាប់ផ្ដើមឆ្លាក់ចារឹក លើផ្ទាំងសិលានោះៗ ដូចសិលាចារឹកភាសាខ្មែរលេខ ៤ បន្ទាត់ ទី ៤-៥ (ក្រុមសិលាចារឹកនគរវត្ត) = "សព្ទមស្តុ ១៤៨៨ សកខាលអក្សត្របុរមី(៥) កើតខែហ មាគ្គសិរ ព្រហស្បតិវារមន្ត្រ... » ។ (សុភមស្តុសករាជ ១៤៨៨ ឆ្នាំខាល ១៥ កើតខែមិគសិរ ថ្ងៃព្រហស្បតិ៍នេះគឺ....) ។

សិលាចារឹកលេខ ២ បន្ទាត់ទី ១០–១១ (ក្រុមសិលាចារឹកនគរវត្ត) = « មន្តិកាុះគ ១៤៩៩ ធ្នូនក្សត្រ (១១) ចតុទ្ទិធិកេតអាសាឍ្យសោរវារ ខ្ញុំអំបស្សយល.... » ។ (នេះគឺកុះដល់សក-រាជ ១៤៩៩ ឆ្នាំជូវ ១៤ កើតខែអាសាធ ថ្ងៃសៅរ៍ខ្ញុំអម្ចាស់យល់... ) ។

---

(១) ពាក្យនេះពិតមែនតែស្លៀងពីច្បាប់ពាក្យព្រោះខ្យល់ក្រោខាងក្នុងត្រូវមានស្រះ , ប៉ុន្តែចំ-ពោះពាក្យនេះយើងទម្លាប់និយាយបញ្ចេញខ្យល់ស្រះ , (សរសេរ ភទ្របទ និយាយភទ្របុទ) ។



គប្បីជ្រាបថា របៀបប្រើសករាជនូវទៅតាមនិវាសក្នុងសម័យបុរាណនោះ គេនិយមប្រើតែមហាសករាជមួយប៉ុណ្ណោះ ។ ឯមហាសករាជនោះកើតក្រោយគ្រិស្តសករាជ ៧៨ ឆ្នាំ ដូច្នេះបើយើងចង់ដឹងជាគ្រិស្តសករាជវិញត្រូវបន្ថែម ៧៨ ឆ្នាំ លើមហាសករាជនោះៗ នឹងបានជ្រាបជាគ្រិស្តសករាជប៉ុន្មានៗ តាមបំណង ។

ឯរឿងណាមួយ ដែលអ្នកនិពន្ធមិនបានប្រើមធ្យោបាយរក្សាទុកនូវកេរ្តិ៍ឈ្មោះ-កាលបរិ-ច្ឆេទរបស់ខ្លួន នៅខាងដើមអត្ថបទឬខាងក្នុងអត្ថបទរបស់ខ្លួនទេ មុខជារកនាមនឹងកាលបរិច្ឆេទរបស់អ្នកនិពន្ធ ដែលបានផ្ដើមនិពន្ធរឿងនោះៗ ពុំឃើញឡើយ ដូចច្បាប់ផ្សេងៗ ច្បាប់ក្រមកេរ្តិ៍កាល កូនចៅ ហៃមហាជន, ច្បាប់ប្រុស-ស្រី...), រឿងព្រេងផ្សេងៗ (អាឡេវ, អាគុង អាសាញ់, សុភាទន្សាយ, ធនញ្ជ័យ...), ក្នុងចំណោមអក្សរសាស្ត្រខាងផ្នែកសាសនាក៏ច្រើន តែមានទំនងដូច្នេះដែរ ដូចជារឿងទសជាតក បឋមសម្ពោធិ រឿងជាតកផ្សេងៗ អានិ-សង្សផ្សេងៗជាដើម ។ គេមិនសូវប្រទះឃើញនាមនឹងកាលបរិច្ឆេទរបស់អ្នកនិពន្ធមុនដំបូងបង្អស់នោះសោះ ។

នៅទីបំផុតខ្ញុំសូមជំរាបថា ការចាត់លំដាប់ប្រវត្តិកាលនៃផ្នែកអក្សរសាស្ត្រខ្មែរនេះ ខ្ញុំបានរៀបចំធ្វើដោយបន្ទាន់ប្រញាប់ដកទៅបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដី នៃវិទ្យាស្ថានជាតិគរុកោ-សល្យឲ្យបានទាន់ពេលវេលា ។ ប៉ុន្តែនោះការសជាលំដាប់តៗ ទៅខ្ញុំនឹងខំប្រឹងស្រាវជ្រាវពិនិត្យរៀបចំ ឬ កែប្រែឲ្យសមរម្យទៅតាមកាលៈទេសៈ ។ ដូច្នេះភាគប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរនេះគង់នៅមានតក់ផ្លង ឬ ភ្លាំងភ្លាត់ ខ្វះខាតខ្លះជាមិនខានដែលខ្ញុំសូមទទួលយកនូវសេចក្ដីពន្យល់-ចំរិះសមហេតុសមផល អំពីសំណាក់អ្នកអានទាំងឡាយដោយក្ដីគោរពដ៏ខ្ពង់ខ្ពស់ ។

ខ្ញុំសូមថ្លែងអំណរអរគុណចំពោះអស់លោកទុកជាមុន ។

ញ៉ុក.ថែម

មជ្ឈដ្ឋានផ្នែកស្រាវជ្រាវនៅវិទ្យាស្ថានជាតិគរុកោសល្យ ក្រុងភ្នំពេញ

— 24 —

## តារាងប្រវត្តិកាលនៃអក្សរសាស្ត្រខ្មែរខ្លះតាំងពីសតវត្សរ៍ទី ១៥ ដល់ទី ១៩ (កំឡុង ៥០០ឆ្នាំ)

| លេខរៀង | ឈ្មោះរឿងផ្សេង ៗ | របៀបនិពន្ធ | នាមអ្នកនិពន្ធ | សតវត្សរ៍ឬគ.ស. | រជ្ជកាលផ្សេង ៗ |
|---|---|---|---|---|---|
| ១ | សិលាចារិកនគរវត្ត | ពាក្យចារិក ខាងចុងជាពាក្យកាព្យ | លោកសីដែលរួបរួម ឯពាក្យកាព្យខាងចុងរបស់បណ្ឌិតជ័យនន្ទ | សតវត្សរ៍ទី ១៥ ដល់ ១៨ | រវាងរាជ្យព្រះបាទធម្មោរាជាទី ១ទល់នឹងរាជ្យព្រះបាទអង្គអេង ។ |
| ២ | (១) រាមកេរ្តិ៍វគ្គ ១ ដល់ ១០<br>" វគ្គ ៧៥ ដល់៨០ | ពាក្យកាព្យ (បទល្បោន)<br>" | ?<br>? | កំឡុងសតវត្សរ៍ទី១៧-១៨<br>?<br>ទី១៨-១៩<br>? | រវាងរាជ្យព្រះបាទជ័យជេដ្ឋាទី ៤ មកទល់នឹងរាជ្យព្រះបាទអង្គអេង<br>រវាងរាជ្យព្រះបាទអង្គអេងមកទល់នឹងរាជ្យព្រះបាទអង្គឌួង |
| ៣ | ជាវរឿង | ពាក្យកាព្យ | ឧកញ៉ាចក្រី (កែវ) | ១៥៣៤ | ព្រះបាទអង្គច័ន្ទទី១ |
| ៤ | ល្បើកអង្គរ | ពាក្យកាព្យ | អ្នកប៉ាង | ១៥៩៨ | ព្រះបាទព្រះរាជសម្ភារ |

(១)–សូមឲ្យមើលនយលក្ខណៈខាងចុងតារាងប្រវត្តិកាលនេះ

— 25 —

| លេខរៀង | ឈ្មោះរឿងផ្សេង ៗ | របៀបនិពន្ធ | នាមអ្នកនិពន្ធ | សតវត្សរ៍ឬគ.ស. | រជ្ជកាលផ្សេង ៗ |
|---|---|---|---|---|---|
| ៥ | កំណាព្យថ្លែងក្តីស្នេហា (សរសើរហេមវត្តមាសជាដើម) | ពាក្យកាព្យ | ព្រះបាទព្រះរាជសម្ភារ | ១៦២៩-១៦៣៤ | ព្រះបាទព្រះរាជសម្ភារ |
| – | ច្បាប់ព្រះរាជសម្ភារ | ពាក្យកាព្យ | ព្រះបាទព្រះរាជសម្ភារ | ១៦២៩-១៦៣៤ | ព្រះបាទព្រះរាជសម្ភារ |
| ៦ | ខ្យងសង្ខ | ពាក្យកាព្យ | ក្រុមព្រះនិពន្ធព្រះបាទជ័យជេដ្ឋា | ១៦៩៣ | ព្រះបាទជ័យជេដ្ឋាទី ៤ |
| ៧ | ព្រះរាជក្រិត្យក្រមផ្សេង ៗ | ពាក្យរាយ | ក្រុមព្រះនិពន្ធព្រះបាទជ័យជេស្ឋា | ១៦៩៣-១៦៩៧ | ព្រះបាទជ័យជេស្ឋា(ពញាសូ) |
| ៨ | ច្បាប់ចាស់ | ពាក្យកាព្យ | ព្រះបាទសត្ថាទី២ | ១៧២២-១៧២៩ | ព្រះបាទសត្ថាទី ២ |
| ៩ | ច្បាប់សុភាសិត | ពាក្យកាព្យ | ឧកញ៉ាវង្សាសារពេជ្រ(នង) | ១៧៩០ | ព្រះបាទអង្គអេង |
| ១០ | លោកន័យជាតក | ពាក្យកាព្យ | – វង្សាក្សត្រី(នង) | ១៧៩៤ | ព្រះបាទអង្គអេង |
| ១១ | បុញ្ញាសាសិរសា | ពាក្យកាព្យ | – វង្សាក្សត្រី(នង) | ១៧៩៧ | ព្រះបាទអង្គអេង |
| ១២ | ក្រុងសុភមិត្រ | ពាក្យកាព្យ | – កោសាធិបតី(កៅ) | ១៧៩៨ | ព្រះបាទអង្គច័ន្ទទី ២ |

| លេខរៀង | ឈ្មោះរឿងផ្សេងៗ | របៀបនិពន្ធ | នាមអ្នកនិពន្ធ | សតវត្សរ៍គ.ស. | រជ្ជកាលផ្សេងៗ |
|---|---|---|---|---|---|
| ២៧ | រឿងទេវន្ត | ពាក្យកាព្យ | អមាត្យក្សត្រី(ម៉ុក) | ១៨៥៩ | ព្រះបាទអង្គដួង |
| ២៨ | រឿងទុំទាវ | " | អមាត្យក្សត្រី(ម៉ុក) | " | » « |
| ២៩ | វិមានចន្ទ | " | ឧកញ៉ាបញ្ញាធិបតី(ម៉ៅម) | " | » « |
| ៣០ | ព្រះសុភិត | " | បណ្ឌិតកោះ | ១៨៦៤ | ព្រះបាទនរោត្តម |
| ៣១ | មរណមាតា | " | ឥន្ទបញ្ញា(អ៊ុក) | ១៨៧៧ | » » |
| ៣២ | កោធិវង្ស | " | ព្រហ្មបរភក្តិ | ១៨៨១ | « « |
| ៣៣ | រឿងអំបែងបែក | " | ឧកញ៉ាសុត្តន្តប្រីជា(ឥន្ទ) | ១៨៨៣ | « « |
| ៣៤ | ចៅភាស | " | ឃុនសុន្ទរពិនិត្យ | ១៨៨៧ | » « |
| ៣៥ | កាព្យសារវិលាសវាសិនី (ច្បាប់តែងកាព្យ) | មេកាព្យ | ឧកញ៉ាសុត្តន្តប្រីជា(ឥន្ទ) | ១៨៨៩ | » » |
| ៣៦ | សុភាសិតច្បាប់ស្រី | ពាក្យកាព្យ | " | ១៨៩០ | « » |
| ៣៧ | លោកនីតិបករណ៍ | ពាក្យកាព្យ | " | " | « » |
| ៣៨ | រឿងសព្វសិទ្ធិ | ពាក្យកាព្យ | ហ្លួងភក្តីអក្សរ(ត៣) | ១៨៩៩ | « « |

— 28 —

| លេខរៀង | ឈ្មោះរឿងផ្សេងៗ | របៀបនិពន្ធ | នាមអ្នកនិពន្ធ | សតវត្សរ៍គ.ស. | រជ្ជកាលផ្សេងៗ |
|---|---|---|---|---|---|
| ៣៩ | សង្ខសិល្បជ័យ | ពាក្យកាព្យ | ឧកញ៉ាវង្សាធិបតី(អ៊ុក) | ? | ព្រះបាទនរោត្តម |
| ៤០ | សាស្ត្រជុំប | » | វិសេស(ខ្ជួង) | ? | ? |
| ៤១ | គតិលោក(១០ក្បាល) | ពាក្យរាយនិងពាក្យកាព្យខ្លះ | ឧកញ៉ាសុត្តន្តប្រីជា(ឥន្ទ) | ១៩២១ | ព្រះបាទស៊ីសុវត្ថិ |
| ៤២ | បឋមសម្ពោធិ | ពាក្យកាព្យបទពោល | " " | ? | " |

(១)រឿងរាមកេរ្តិ៍ ដែលមានគម្ពីរដើម ហៅថា រាមាយណៈ គេបាននិពន្ធជាភាសាសំស្ក្រឹតមុនដំបូងបង្អស់ ។ គម្ពីរកាព្យនេះ គេបានទុកដាក់ជាស្នាដៃនៃអ្នកកវីនិពន្ធតំណៀបម្នាក់ឈ្មោះវាល្មិកិ ដែលបាននិពន្ធជាពាក្យកាព្យទុកក្នុងភាសាសំស្ក្រឹតកំឡុង ព.ស. ៧៥០ (រវាងសតវត្សរ៍ទី ៣ នៃគ.ស.) ។ រឿងនេះបានផ្សាយចូលមកក្នុងស្រុកខ្មែរយើង ក្នុងសម័យអង្គរ ដ្បិតរឿងរាមកេរ្តិ៍គេប្រហែលជាគេបាននិពន្ធឡើងជាភាសាខ្មែរ តាំងពីកំឡុងសតវត្សរ៍ទី ១១-១២ នៃគ្រិស្តសករាជ ព្រោះមានរូបចម្លាក់រឿងនេះ នៅនឹងជញ្ជាំងប្រាសាទអង្គរតាំងអំពីកាលណោះដែរ ប៉ុន្តែដែលយើងទុកដាក់ជារឿងនេះ (បំពោះរឿងរាមកេរ្តិ៍បោះពុម្ពជាសៀវភៅ ១) គេបាននិពន្ធឡើងក្នុងកំឡុងសតវត្សរ៍ទី ១៧-១៨ ទៅវិញ ដោយអនុលោមទៅតាមពាក្យពេចន៍–សំដីថ្វីមាត់–សំនួនវោហារនៃរឿងរាមកេរ្តិ៍នេះ មិនមែនហាក់-ហួសពីសតវត្សរ៍ទី ១៧ ឡើងទៅទេ ។

— 29 —

*ស្រង់ចេញពីទស្សនាវដ្តីវិទ្យាស្ថានជាតិគរុកោសល្យ, ១៩៥៩, លេខ ២, ទំព័រ២០ដល់២៩,*
*អត្ថបទសិក្សានិពន្ធដោយសាស្ត្រាចារ្យ ញ៉ុកថែម។*

## LA VIE A L'INSTITUT

# Recrutement des Elèves-Professeurs

La Formation des Professeurs du Ier cycle de l'Enseignement Secondaire est à l'heure actuelle la tâche principale de l'Institut National Pédagogique.

Les conditions d'admission à l'Institut sont prévues dans l'article 3 du Kret n° 438 NS en date du 10-7-58, à savoir :

1o- Les candidats titulaires du Baccalauréat peuvent être admis d'office.

2o- Les Normaliens ayant échoué au Baccalauréat Ière partie et les instituteurs diplômés comptant au moins 3 ans de service sont recrutés par voie de concours.

Les épreuves du Concours de Recrutement des élèves professeurs sont destinées à permettre aux membres du Jury, de vérifier que les candidats sont aptes, non pas à enseigner immédiatement dans un collège du Royaume, mais à profiter au mieux des enseignements donnés à l'Institut.

Ces épreuves comprennent, pour chaque section :

A L'ECRIT :

1o- Une épreuve portant sur la discipline optée par le candidat.

Durée : 3h. - Coefficient 2.

2o- Une épreuve de Culture Générale

Durée : 3h. - Coefficient I.

A L'ORAL

Une interrogation sur la spécialité du candidat - Coefficient 2.

Les principales épreuves écrites données au concours de la session du 4 Octobre 1958 ont été les suivantes :



### I- Option «KHMER»

a) Discipline Optée : : deux sujets au choix du candidat

ប្រធានទី១: គេថា "គ្មានអ្វីរៀនទេក្នុងអក្សរសាស្ត្រខ្មែរ" ។

តើអ្នកអាចយោបល់ដូចម្ដេចចំពោះមតិបែបនេះ ហើយតើអ្នកនឹងបង្រៀនអក្សរសាស្ត្រខ្មែរបែបណា ទើបធ្វើឲ្យសិស្សចូលចិត្តនឹងសិក្សាផង ព្រមទាំងឲ្យមានអ្វីនឹងបង្រៀនផង ? ។

1er Sujet : « On dit qu'il n'y a rien à étudier dans la littérature khmère».

Que pensez-vous de cette opinion ? Et comment enseigneriez-vous la littérature khmère pour que vos élèves s'intéressent à cette discipline, et que vous ayez «quelque chose» à faire étudier ?

ប្រធានទី២. "នាងកេសរីនីមានទុក្ខដោយសារកម្មផលក្នុងអតីតកាល នាងកាកីមានទុក្ខដោយសារបុព្វហេតុក្នុងបច្ចុប្បន្នកាល,, ។

តើការប្រៀបធៀបរវាងតួអង្គទាំងពីរនេះអាចបង្ហាញនូវបញ្ហាសំខាន់ៗ ក្នុងអក្សរសាស្ត្រខ្មែរដែរឬទេ ?។

2ème Sujet : « Néang KESANI souffre à cause de son Karma dans le passé; tandis que Néang KAKEI souffre à cause de son présent.

Comment l'étude comparative de ces deux héroïnes met-elle en relief quelques principaux thèmes de la littérature khmère ?

b) Culture Générale (en Français)

Sujet : «Quelles sont, d'après vous, les vertus qu'un homme accompli devrait avoir?»

### Option «FRANÇAIS»

a) Discipline Optée : (en français)

Deux sujets : au choix du candidat.

1o- A notre époque, grâce à la machine, l'homme tend à devenir le maître de la nature.

Est-ce cela seulement qui, à votre avis, constitue le progrès ? - Que voudriez vous voir ajouter à cette force matérielle de l'homme ?

2o. Madame de Staël a écrit : « Au XVIIIème siècle, la littérature n'est plus un art seulement, elle devient une arme pour l'esprit humain.»

Vous développerez ce jugement en vous servant des œuvres de Voltaire et de J.J. Rousseau.

b) CULTURE GENERALE (en Khmer)

Sujet :

តាមយោបល់អ្នកតើមនុស្សត្រូវមានគុណសម្បត្តិអ្វីខ្លះ ទើបបានពេញលេញជាមនុស្ស ៗ

---

## - Option « HISTOIRE »

a - Discipline optée (en français)

— Deux sujets : au choix du candidat.

1o. Les Européens en Chine de 1842 aux premières années du XXème siècle.

2o. Quels sont les principaux traits de la civilisation du XIXème siècle ?

b - Culture générale (en Khmer)
même sujet que pour les autres options

---

## - Option « GEOGRAPHIE »

a - Discipline optée (en français)

— Deux sujets : au choix du candidat.

1o. Influence du relief, du climat et de la nature du sol sur les différents types d'activités agricoles du Cambodge.

2o. Les principales richesses du sous-sol de la France.

b - Culture générale (en Khmer)
même sujet que pour les autres options.



## - Option « SCIENCES NATURELLES »

a - Discipline optée (en français)

— Sujet : L'œil et la vue.

a-) Description de l'œil (organes annexes, globe oculaire)

b-) Mécanisme de la vision

c-) Anomalies de la vision.

b - Culture générale : en Khmer (même Sujet)

---

## - Option « PHYSIQUE & CHIMIE »

a - Discipline optée

Questions de cours : une des questions ci-après au choix du candidat :

1o. Lois qualitatives et quantitatives de l'électrolyse

2o. Le Benzène

### Problème obligatoire

1o. Un petit objet est placé à 18 cm d'une lentille $L_1$. Déterminer sa distance focale sachant que l'image se forme sur un écran à 22,5 cm de $L_1$.

2o. Pour mesurer la convergence d'une lentille $L_2$, on l'accole à une lentille convergente étalon de 30 dioptries et l'on forme sur un écran l'image de l'objet. Dans une première position l'écran se trouve à 80 cm vers les lentilles : on doit alors reculer l'écran de 20 cm pour obtenir de nouveau une image nette. Calculer la distance focale de $L_2$.

3o. Les lentilles $L_1$ et $L_2$ sont disposées dans un tube à 6 cm l'une de l'autre, les deux axes principaux sont confondus $L_2$ sert d'objectif, $L_1$ d'oculaire; on vise un objet à l'infini. Où se forme l'image ?

Tracer la marche d'un faisceau.

Calculer le grossissement. On admet que les lentilles sont d'épaisseur négligeable et que l'objet sont plans et placés perpendiculairement à l'axe principal.

b - Culture générale ( en khmer )

même sujet que pour les autres options

## RESULTATS DU CONCOURS

(SESSION DU 4 OCTOBRE 1958)

| No d'ordre | DISCIPLINES OPTEES | NOMBRE DES CANDIDATS | | | OBSERVATIONS |
|---|---|---|---|---|---|
| | | inscrits | admis | sur liste de réserve | |
| 1 | KHMER | 22 | 10 | 1 | |
| 2 | FRANÇAIS | 20 | 5 | 2 | |
| 3 | HISTOIRE | 5 | 2 | 0 | |
| 4 | GEOGRAPHIE | 13 | 6 | 2 | |
| 5 | SCIENCES NATURELLES | 16 | 4 | 2 | |
| 6 | ANGLAIS | 13 | 5 | 0 | |
| 7 | MATHEMATIQUES | 31 | 6 | 3 | |
| 8 | PHYSIQUE & CHIMIE | 8 | 4 | 1 | |
| | TOTAL. . . . | 128 | 42 | 11 | |

La majorité des admis est composée d'instituteurs ayant une longue expérience pédagogique dans les lycées et collèges. Quelques uns occupent même des postes de Directeurs d'Etablissements Secondaires du Ier cycle.

Par ailleurs, malgré la moyenne des notes assez élevée obtenue par les candidats, l'Institut National Pédagogique n'a pu les recevoir tous, à cause du nombre déjà important d'Elèves-Professeurs inscrits d'office. Il y en a 45 qui sont titulaires du Baccalauréat.

Quant aux admis sur la liste de réserve, ils ont été orientés vers les disciplines qui ne comportaient pas assez d'étudiants, et qui ont des rapports étroits avec les disciplines initialement choisies.

— 34 —

## Liste nominative des candidats définitivement admis

(PAR ORDRE DE MERITE)

### I - Option «KHMER»

1er M. Thach Ba
2è - Koy Thuon
3è - Tiv Ol
4è - Khuon Sokhamphu
4è - Leang Hap An
6è - Duch Phan
7è - Pum Chhay
8è - Thach Ce Hoanh
9è - Seng Bunthan
9è Mme Peng Ponn, née Ker Kanoureth

Liste de réserve : Sau Vandy

### II - Option «FRANÇAIS»

1er M. Khouth Chring
2è - Meng Dek
3è - Kau Lon
4è Mme San Sophon, née Yean Sabon
5é Melle Meas Saèm Henriette Romduol

Liste de réserve : On Chuon
Thach Nhuong

### III - Option «HISTOIRE»

1ère Mme Ho Bun Lay, née Thong That
2è M. Pen Navuth

— 35 —

និស្សិតសាស្ត្រាចារ្យនៅវិទ្យាស្ថានជាតិគរុកោសល្យជំនាន់ឆ្នាំ១៩៥៩។ ស្រង់ចេញពីទស្សនាវដ្ដីវិទ្យាស្ថានជាតិគរុកោសល្យ,លេខ២, ១៩៥៩។